**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៨ សរ.ណន

## សារាចរណែនាំ

## ស្តីពី

## ការពង្រឹង និងជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងសភាពការណ៍ថ្មី

ទេសចរណ៍គឺជាវិស័យអាទិភាពមួយក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិ។ ប៉ុន្មានឆ្នាំចុងក្រោយនេះចំនួនភ្ញៀវទេសចរមកដល់កម្ពុជាមានបរិមាណកើនឡើងពី ២៥%-៣០% ដែលនាំឱ្យវិស័យទេសចរណ៍កម្ពុជាយើងបានបង្ហាញនូវតួនាទីពិតប្រាកដក្នុងការនាំមកនូវចំណូលជាតិ និងបង្កើនការងារជូនប្រជាពលរដ្ឋរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។

ដោយព្រឹត្តិការណ៍ភេរវកម្មថ្ងៃទី១១ ខែកញ្ញា នៅទីក្រុងញូយ៉ក និងវ៉ាស៊ីងតោនសហរដ្ឋអាមេរិកបានជះឥទ្ធិពលប្រែប្រួលផ្ទាល់ដល់កំណើនទេសចរណ៍ពិភពលោក ហើយបានប៉ះពាល់មួយចំណែកដល់កំណើនទេសចរណ៍នៅប្រទេសកម្ពុជា ប៉ុន្តែបច្ចុប្បន្នស្ថានការណ៍ទេសចរណ៍កំពុងតែវិលត្រឡប់ជាបណ្តើរៗមកកាន់សភាពដើមវិញហើយ។

ដោយកម្ពុជាយើងជាប្រទេសមួយសម្បូរណ៍ទៅដោយសក្តានុពលវប្បធម៌-ធម្មជាតិ មានអច្ឆរិយៈវត្ថុពិភពលោក សំរាប់ទាក់ទាញភ្ញៀវទេសចរដែលភាគច្រើនកំពុងមាននិន្នាការផ្តោតទៅលើទេសចរណ៍បែបវប្បធម៌និងធម្មជាតិ, ស្របនឹងប្រទេសយើងកំពុងស្ថិតក្នុងសន្តិភាព និងស្ថេរភាពនយោបាយពេញលេញផងកម្ពុជាត្រូវត្រៀមលក្ខណៈសមស្របដើម្បីពង្រឹង និងជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងសភាពការណ៍ថ្មីឱ្យរក្សាបានកំណើនកាន់តែប្រសើរឡើងថែមទៀត

### រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម៖

១- អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ធ្វើការសម្របសម្រួលនិងសហការណ៍ជាមួយ ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងពត៌មាន និងអាជ្ញាធរអប្សរា ពិគ្រោះពិភាក្សាគ្នាអំពី៖

- គោលដៅទេសចរណ៍ជាអាទិភាព និងសុវត្ថិភាពសំរាប់ភ្ញៀវទេសចរ
- លទ្ធភាពបង្កើតសកម្មភាពសង្គម និងការកំសាន្តសំរាប់បំពេញបន្ថែមកម្មវិធីរបស់ភ្ញៀវទេសចរមានជាអាទិ៍សិល្បៈ ទស្សនីយភាព របាំ ល្បែងប្រជាប្រិយ និងកីឡា។ល។
- ជំរុញការឃោសនាផ្សព្វផ្សាយតាមគ្រប់មធ្យោបាយនិងគ្រប់រូបភាព ដើម្បីទាក់ទាញ លើកទឹកចិត្តភ្ញៀវទេសចរ។

២_ ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋាននគរបាលជាតិ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវយកចិត្តទុកដាក់ និងចាត់វិធានការជាបន្ទាន់លើបែបបទផ្តល់ទិដ្ឋាការដល់ភ្ញៀវទេសចរនៅគ្រប់ច្រកទ្វារអន្តរជាតិ ទាំងផ្លូវអាកាស ផ្លូវគោក ផ្លូវទឹក ធ្វើយ៉ាងណាឱ្យបានឆាប់រហ័ស តែក្នុងស្មារតីពង្រឹងសន្តិសុខនិងសុវត្ថិភាព។ ទន្ទឹមនឹងនេះត្រូវសហការណ៍ជាមួយអាជ្ញាធរអាកាសចរស៊ីវិល កងរាជអាវុធហត្ថជាតិលើផ្ទៃប្រទេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ទីចាត់ការគយនិងរដ្ឋាករ) ក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកាំកុងត្រូល), អាជ្ញាធរខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវពង្រឹងបង្កើននូវតួនាទីសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាការពារ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងផ្តល់ភាពងាយស្រួលក្នុងការត្រួតពិនិត្យឆ្លងកាត់របស់ភ្ញៀវទេសចរ ពិសេសនៅតាមច្រកទ្វារអន្តរជាតិទាំងអស់ និងតាមមណ្ឌលកំសាន្តនានាឱ្យបានហ្មត់ចត់ល្អ ត្រូវចៀសវាងដាច់ខាតនូវការឆ្លៀតឱកាសពង្រឹងសន្តិសុខបង្កភាពលំបាកដល់ដំណើរមកដល់នៃភ្ញៀវទេសចរ។

៣_ ក្រសួងទេសចរណ៍ត្រូវខិតខំបង្កើនឱ្យបានខ្លាំងក្លានូវគុណភាពសេវាកម្មទេសចរណ៍ទាំងឡាយរួមទាំងការថែរក្សាអនាម័យ សណ្តាប់ធ្នាប់ ផ្លាកសញ្ញាពតិមាន នៅតាមរមណីយដ្ឋានទេសចរណ៍ និងមណ្ឌលកំសាន្តនានាឱ្យបានប្រសើរ។ ទន្ទឹមនឹងនេះត្រូវបង្កើតកម្មវិធីយល់ដឹងអំពីសារៈប្រយោជន៍ទេសចរណ៍ដល់ប្រជាពលរដ្ឋ, ចូលរួមចំណែកធ្វើបដិសណ្ឋារកិច្ច និងផ្តល់នូវភាពស្វាគមន៍ជូនភ្ញៀវឱ្យបានល្អដោយរក្សានូវប្រពៃណីខ្មែរ។ អាជ្ញាធរអប្សរាត្រូវខិតខំរៀបចំបង្កើនគុណភាពសេវាកម្មដូចខាងលើនៅក្នុងតំបន់ឧទ្យានអង្គររួមទាំងហេដ្ឋារចនាសម្ព័ន្ធ សេវាសុខាភិបាល សេវាទូរគមនាគមន៍ និងជំរុញអនុវត្តឱ្យជោគជ័យផែនការសកម្មភាពទាំងឡាយដែលបានគ្រោងទុក។

៤_ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំង៣ប្រការខាងលើត្រូវពង្រឹងការអនុវត្តអនុក្រឹត្យលេខ ៦៤អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលស្តីពី ការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ត្រូវយកចិត្តទុកដាក់ដល់ការកែសម្រួល

រចនាសម្ព័ន្ធ និងមូលដ្ឋានសំភារៈ សំរួលដល់បែបបទធ្វើដំណើរ ពិសេសអាគារអ្នកដំណើរនៅច្រកទ្វារអន្តរជាតិ ពោធិ៍ចិនតុង សៀមរាប ប៉ោយប៉ែត បាវិត ជាបន្ទាន់។

៥- ក្រសួងសាធារណការនិងដឹកជញ្ជូន កងវិស្វកម្មយោធពលខេមរភូមិន្ទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរខេត្ត-ក្រុង ត្រូវជំរុញការស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ទៅកាន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានអាទិភាពសំខាន់ៗទាំងឡាយតាមគ្រប់លទ្ធភាពទាំងអស់ ហើយត្រូវប្រមូលផ្តុំយកចិត្តទុកដាក់ជួយដល់អាជ្ញាធរខេត្តសៀមរាប អាជ្ញាធរអប្សារា ក្នុងការជួសជុលថ្នល់ ការដាក់ភ្លើងបំភ្លឺ (ព្រលានយន្តហោះ-ក្រុងសៀមរាប-អង្គរវត្ត) និងសេវាទូរគមនាគមន៍សាធារណៈក្នុងក្រុងសៀមរាប និងតំបន់អង្គរឱ្យបានឆាប់រហ័ស។

៦- អាជ្ញាធរជាតិទេសចរណ៍កម្ពុជា សម្របសម្រួលនិងសហការណ៍ជាមួយ ក្រសួងទេសចរណ៍ អាជ្ញាធរអប្សារា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជនពិគ្រោះពិភាក្សាផ្លាស់ប្តូរយោបល់គ្នាអំពី៖

- ចលនាជម្រុញក្រុមហ៊ុនវិនិយោគដែលមានចំណូលផ្ទាល់ពីវិស័យទេសចរណ៍ មានជាអាទិ៍ក្រុមហ៊ុនគ្រប់គ្រងព្រលានយន្តហោះ ក្រុមហ៊ុនទទួលលក់សំបុត្រចូលទស្សនាប្រាសាទ ឱ្យរួមចំណែកក្នុងការឃោសនាទាក់ទាញភ្ញៀវទេសចរពីក្រៅប្រទេសចំពោះមុខសញ្ញាទីផ្សារជាអាទិភាពនានា ឬរួមចំណែកបន្ថយអប្បរមានៃចំណាយរបស់ភ្ញៀវ។
- យុទ្ធសាស្ត្រជំរុញ និងលើកទឹកចិត្តឱ្យមានការបង្កើតសហគ្រាសតូច-មធ្យមបំរើវិស័យទេសចរណ៍។

៧- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវយកចិត្តទុកដាក់៖

- រៀបចំគាំពារស្តារប្រាសាទ, ជួសជុលរូបបដិមាករ និងប្រព័ន្ធរចនាបទក្បាច់បេតិកភ័ណ្ឌ និងកែលំអ បរិស្ថានវប្បធម៌ ទាំងឡាយណាដែលស្ថិតក្រៅតំបន់គ្រប់គ្រងរបស់អាជ្ញាធរអប្សារា,
- កែសម្រួលកម្មវិធីចូលទស្សនាសារមន្ទីរ និងរៀបចំសំដែងសិល្បៈទស្សនីយភាពជូនភ្ញៀវទស្សនា,
- ពង្រឹងការគ្រប់គ្រងមូលដ្ឋានសិប្បកម្មផលិតនិងលក់ផ្លូវវត្ថុអនុស្សាវរីយ៍សិល្បៈវប្បធម៌នៅគ្រប់តំបន់អាទិភាពនៃគោលដៅទេសចរណ៍។

៨- ដើម្បីអនុវត្តកិច្ចការនេះឱ្យមានប្រសិទ្ធិភាព អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរអប្សារា ត្រូវសម្របសម្រួល និងសហការរៀបចំយុទ្ធនាការពិសេសមួយ ដែលត្រូវមានការចូលរួម និងគាំទ្រពីគ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរ និងផ្នែកឯកជនពាក់ព័ន្ធទាំងអស់។

ទទួលបានទូវសារាចរណែនាំនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន អាជ្ញាធរ និងស្ថាប័ន ពាក់ព័ន្ធត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានទទួលលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ